# ឈ្មោះទេពធីតា តាមសៀវភៅពិធីទានសមាសថា

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃអាទិត្យ ទេពធីតាឈ្មោះ **ទុង្សាទេវី**

សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ( ផ្លែល្វា )

ទ្រង់អាវុធ ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេងទ្រង់ស័ង្ខ ពាហនៈគង់លើគ្រុឌ។

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃចន្ទ ទេពធីតាឈ្មោះ **គោរាគទេវី**

សៀតផ្កាអង្គាបុស្ប ពាក់កែវមុក្តា ភក្សាហារតេលំ( ប្រេង )

ទ្រង់អាវុធ ព្រះហស្តស្តាំទ្រង់ព្រះខ័ន ព្រះហស្តឆ្វេងទ្រង់ឈើច្រត់ ពាហនៈព្យគ្ឃៈ( ខ្លា ) ។

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃអង្គារ ទេពធីតាឈ្មោះ **រាក្សសាទេវី**

សៀតផ្កាឈូករតន៍ ពាក់កែវមនោហរា ភក្សាហារលោហិត( ឈាម )

ព្រះហស្តស្តាំទ្រង់ត្រីសូលិ៍ ព្រះហស្តឆ្វេងទ្រង់ធ្នូ ពាហនៈអស្សតរ ។

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃពុធ ទេពធីតាឈ្មោះ **មណ្ឌាទេវី**

សៀតផ្កាចម្ប៉ា ពាក់កែវពិទូរ្យ ភក្សាហារទឹកដោះស្រស់

ព្រះហស្តស្តាំទ្រង់ម្ជុល ព្រះហស្តឆ្វេងទ្រង់ឈើច្រត់ ពាហនៈលា។

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃព្រហស្បតិ៍ ទេពធីតាឈ្មោះ **កិរិណីទេវី**

សៀតផ្កាមន្ទា ពាក់កែវមរកត ភក្សាហារសណ្តែក-ល្ង

អាវុធ ព្រះហស្តស្តាំទ្រង់ខែល ព្រះហស្តឆ្វេងទ្រង់កាំភ្លើង ពាហនៈគជសា( ដំរី ) ។

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃសុក្រ ទេពធីតាឈ្មោះ **កិមិរាទេវី**

សៀតផ្កាចង្កុលណី ពាក់កែវបុស្សរាគ័ម ភក្សាហារចេកណាំវ៉ា

ព្រះហស្តស្តាំទ្រង់ព្រះខ័ន ព្រះហស្តឆ្វេងទ្រង់ពិណ ពាហនៈហិង្សៈ( ក្របី ) ។

បើសង្ក្រាន្តថ្ងៃដំបូង ជាថ្ងៃសៅរ៍ ទេពធីតាឈ្មោះ **មហោទរាទេវី**

សៀតផ្កាត្រកៀត ពាក់កែវនិលរតន៍ ភក្សាហារសាច់ទ្រាយ

ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេងទ្រង់ត្រីសូលិ៍ ពាហនៈមយូរា( ក្ងោក ) ។

ចម្លងជូនដោយខ្ញុំបាទ **វ៉ាន់ អ៊ុង** ព.ស.២៥៥៥ គ.ស.២០១២

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៤